រៀបចំផលិតដោយ NSW HEALTH DEPARTMENT
Khmer
April 2004
[BHC-6975]

# កិច្ចការពារកុមារនិងជនយុវវ័យ និងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងផ្តល់សេវាសហគមន៍ (Department of Community Services)

## Protecting Children and Young People and reporting to the Department of Community Services

អត្ថបទខាងក្រោមនេះរៀបចំឡើងដោយក្រសួងសុខាភិបាលរដ្ឋញូវសៅវ៉េលស៍។

ជួនកាលការយកកុមារទៅកាន់សេវា(កិច្ចបំរើ)សុខាភិបាលអាចជាបទពិសោធន៍ដ៏លំបាកមួយ សំរាប់មាតាបិតា។ ការណ៍នេះអាចមានភាពកាន់តែលំបាកយ៉ាប់យ៉ឺនឡើង នៅក្នុងគ្រាដែល ភ្នាក់ងារសុខាភិបាលណាមួយ មានការបារម្ភអំពីសុខុមាលភាពរបស់ក្មេង ហើយត្រូវទាក់ទងក្រសួងផ្តល់សេវាសហគមន៍ -Department of Community Services (DoCs) ។

ជាការសំខាន់ណាស់ដែលមាតាបិតាដឹងយល់ថា នៅក្នុងច្បាប់(ថែទាំនិងការពារ) កុមារនិងជនយុវវ័យ ឆ្នាំ១៩៩៨ គ្រប់ភ្នាក់ងារសុខាភិបាលទាំងអស់ ដែលមានការបារម្ភអំពីក្មេងណាមួយដែលអាចប្រឈមមុខនឹងគ្រោះថ្នាក់នៃការបំពានធ្វើបាប ឬក៏ត្រូវគេទុកចោលដោយគ្មានការមើលថែទាំនោះ ត្រូវតែរាយការណ៍ទៅកាន់ក្រសួងផ្តល់សេវាសហគមន៍ (DoCS)។បើសិន ជាមានសញ្ញាឬតម្រុយណាមួយឲ្យដឹងថា ក្មេងណាមួយអាចប្រឈមមុខនឹងគ្រោះថ្នាក់នោះ ភ្នាក់ងារសុខាភិបាលគ្មានជំរើសអ្វី ក្រៅតែអំពីការធ្វើរបាយការណ៍ឡើយ។ ការណ៍នេះអាចនាំឲ្យមាតាបិតាមានការភាន់ច្រឡំ ហើយក៏ធ្វើឲ្យភ្នាក់ងារសុខាភិបាលមានការលំបាកដែរ។

កុមារឬក៏ជនយុវវ័យអាច "ប្រឈមមុខនឹងគ្រោះថ្នាក់" នៅពេលដែលគេបាន ឬក៏ប្រហែលជា:

- ទទួលរងការធ្វើបាបឬបំពានតាមផ្លូវភេទឬរាងកាយ។
- រស់នៅក្នុងគេហដ្ឋានមួយដែលមានអំពើហិង្សា។
- មានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ ដោយសារឥរិយាបថរបស់មាតាបិតា។
- មិនបានទទួលគ្រឿងសម្ភារ:សំខាន់ចាំបាច់ មានដូចជាម្ហូបអាហារ សុវត្ថិភាព សំលៀកបំពាក់និងការស្រឡាញ់។
- ឬក៏អ្នកដែលមើលថែទាំក្មេងនិងជនយុវវ័យទាំងនោះ មិនអាចឬក៏មិនចង់រៀបចំឲ្យមានការថែទាំសុខភាពសំរាប់អ្នកទាំងនោះបាន។

បញ្ហាទាំងនេះមានលើកឡើងថែមទៀត នៅក្នុងប័ណ្ណព័ត៌មានផ្សេងៗទៀតផលិតឡើងដោយអង្គការ Multicultural Communication (ទំនាក់ទំនងពហុវប្បធម៌)។

តួនាទីរបស់ភ្នាក់ងារសុខាភិបាល គឺត្រូវធ្វើការជាមួយនឹងគ្រួសារទាំងពួង ដើម្បីជួយពួកគេឲ្យមានសុខភាពបរិបូរ។ បើទុកណាជាទូទៅភ្នាក់ងារសុខាភិបាលត្រូវធ្វើរបាយការណ៍មួយទៅជូនក្រសួងផ្តល់សេវាសហគមន៍ (DoCS) ក៏ដោយ ក៏គេនៅតែចង់ធ្វើការជាមួយនឹងគ្រួសារនោះដែរ។ តួនាទីរបស់ភ្នាក់ងារសុខាភិបាល គឺមិនមែនសំរាប់

បង្ហាញថា តើកុមារ នោះបានទទួលរងការបំពានធ្វើបាប ឬក៏ត្រូវគេទុកចោលមិនមើលថែទាំនោះទេ ប៉ុន្តែភ្នាក់ងារនោះមានតួនាទីត្រឹមតែធ្វើសេចក្តីរាយការណ៍អំពីលទ្ធភាពនៃការប្រឈមមុខ នឹងគ្រោះថ្នាក់ទៅជូនក្រសួងផ្តល់សេវាសហគមន៍ (DoCS)ប៉ុណ្ណោះ។

ក្រសួងផ្តល់សេវាសហគមន៍ (DoCS) មានតួនាទីដើម្បីបង្ហាញថា តើកុមារនោះបានទទួលរងការបំពានធ្វើបាប ឬក៏យ៉ាងណា។ នរណាមួយដែលមានការបារម្ភអំពីសុវត្ថិភាព សុខុមាលភាព ឬសុខភាពរបស់ក្មេងណាមួយ អាចទាក់ទងការផ្តល់ជំនួយតាម ទូរស័ព្ទដែលមានលេខ 132-111 (ប្រតិបត្តិការ២៤ម៉ោងក្នុងមួយថ្ងៃ តែជាភាសាអង់គ្លេសប៉ុណ្ណោះ) ។ បើសិនជា លោកអ្នកត្រូវការជំនួយដើម្បីប្រើទូរស័ព្ទជាភាសាអង់គ្លេស សូមទូរស័ព្ទទៅសេវាបកប្រែភាសា (TIS) លេខ 131 450 ។

ការដែលក្រសួងផ្តល់សេវាសហគមន៍ (DoCS) ចូលរួមពាក់ព័ន្ធជាមួយនឹងគ្រួសារណាមួយ ជាញឹកញយតែងតែមានការលំបាក ក៏ប៉ុន្តែ ទង្វើនេះក៏អាចនាំមកនូវបទពិសោធន៍វិជ្ជមានផងដែរ។ នៅពេលដែលមាន របាយការណ៍ធ្វើឡើង:

- អាចមានការសំរេចថា មិនចាំបាច់ធ្វើការតាមដានឡើយ។
- ក្រសួងផ្តល់សេវាសហគមន៍ (DoCS) អាចជួបជាមួយនឹងគ្រួសារ ដើម្បីស្វែងយល់ថាតើអ្វីៗដំណើរការជាធម្មតាទេ។
- ក្រសួងផ្តល់សេវាសហគមន៍ (DoCS) អាចជួបជាមួយនឹងគ្រួសារដើម្បីពិភាក្សារកវិធីសំរាប់ជួយរក្សាឲ្យកុមារមានសុវត្ថិភាព ដោយរួមទាំងការបញ្ជូនទៅកាន់អង្គការដទៃទៀត ដែលអាចជួយដល់មាតាបិតាផង។
- ក្រសួងផ្តល់សេវាសហគមន៍ (DoCs) អាចសំរេចចិត្តថា បណ្តឹងផ្លូវច្បាប់ គឺជាតម្រូវការចាំបាច់ សំរាប់ក្រុមគ្រួសារមួយចំនួនតូច ដើម្បីរក្សានូវសុវត្ថិភាពរបស់កុមារ។

លោកអ្នកអាចស្វែងរកពត៌មានអំពីសុខភាពថែមទៀតជាភាសាលោកអ្នក នៅតាមគេហទំព័រនៃអ៊ិនធឺណិត របស់អង្គការ Multicultural Communication (ទំនាក់ទំនងពហុវប្បធម៌) នៅឯ

http://mhcs.health.nsw.gov.au ។

លេខទូរស័ព្ទទាំងនេះគឺជាលេខត្រឹមត្រូវនៅគ្រាដែលបោះពុម្ពផ្សាយ ប៉ុន្តែមិនបានទទួលការកែតម្រូវជាប្រចាំទេ។ លោកអ្នកប្រហែលជាត្រូវតែឆែករកលេខទូរស័ព្ទទាំងនេះ នៅតាមសៀវភៅទូរស័ព្ទហើយ៕